**Alert.seattle.gov/hazmat** (ការជូនដំណឹង.seattle.រដ្ឋាភិបាល/សារធាតុមានគ្រោះថ្នាក់)

**ការណ៍ពិត ៖** សារធាតុមានគ្រោះថ្នាក់ បង្ករឱ្យមានហានិភ័យធ្ងន់ធ្ងរ ចំពោះជីវិត សុខភាព ឬទ្រព្យសម្បត្តិ នៅពេលមានការចាត់ចែង មិនបានត្រឹមត្រូវ ដែលនាំឱ្យមានការកំពុប ជ្រាប ឬធ្លាយចំហាយពុល ។ សារធាតុទាំងនេះ មិនអាចមើលឃើញ ហិតក្លិនដឹង ឬស្គាល់ដោយរសជាតិនោះទេ ។

**អ្វីដែលត្រូវធ្វើ ៖**

- ស្តាប់តាមការណែនាំនានា ពីអាជ្ញាធរមូលដ្ឋាន ។ លោកអ្នកអាចត្រូវបានប្រាប់ ឱ្យជ្រកនៅនឹងកន្លែង ឬជម្លៀសចេញ អាស្រ័យតាមស្ថានភាព ។
- ប្រសិនបើមានការប្រាប់ឱ្យជ្រកនៅនឹងកន្លែង នាំក្រុមគ្រួសារ និងសត្វចិញ្ចឹមរបស់លោកអ្នកឱ្យនៅក្នុងផ្ទះ ។ បិទទ្វារ បង្អួច និងឡដុតកំដៅ ។ ដាក់កន្សែងពោះគោសើម នៅច្រកទ្វារ ចូល និងច្រកផ្សេងៗ ទៀត ដែលកំសួលពីខាងក្រៅអាចចូលបាន ។ បិទកង្ហារ ម៉ាស៊ីនត្រជាក់ ប្រព័ន្ធកំដៅ និងប្រព័ន្ធផ្សេងទៀត ដែលបូមខ្យល់ពីខាងក្រៅ ។ ត្រៀមលក្ខណៈនឹងធ្វើការកែច្នៃ ហើយប្រើអ្វីដែលលោកអ្នកមាននៅក្នុងដៃ ដើម្បីបិទរន្ធចន្លោះ ដើម្បីបិទបាំងខ្លួនលោកអ្នក ពីខ្យល់ខាងក្រៅ ។
- ប្រសិនបើមានការប្រាប់ឱ្យជម្លៀសចេញ សូមធ្វើតាមភ្លាម ។ ទៅតាមផ្លូវដែលបានណែនាំប្រាប់ ដូចមានផ្តល់ជូននៅក្នុងសេចក្តីជូនដំណឹងអំពីការជម្លៀសចេញ ។ ផ្លូវមួយចំនួនអាចមានផ្លាកសញ្ញា ដាក់នៅតាមបណ្តោយផ្លូវ និងវិថីធំៗ ។
- ប្រសិនបើលោកអ្នកឃើញមានការកំពុបសារធាតុ ត្រូវចាកចេញពីតំបន់ ប្រាប់អ្នកផ្សេងទៀតដោយស្ងប់ស្ងៀម ឱ្យនៅឱ្យឆ្ងាយ ហើយទូរស័ព្ទទៅលេខ 911 ដើម្បីរាយការណ៍ ពីឧបទ្ទវហេតុ។
- ប្រសិនបើលោកអ្នកគិតថា លោកអ្នកប៉ះពាល់សារធាតុគីមី ឬសារធាតុជីវសាស្ត្រ ទូរស័ព្ទទៅមជ្ឈមណ្ឌលគ្រប់គ្រងសារធាតុពុល (1-800-222-1222) ឬស្វែងរកការព្យាបាលផ្នែកវេជ្ជសាស្ត្រសមស្រប ។
- ស្តាប់វិទ្យុ ដើម្បីទទួលបានបច្ចុប្បន្នភាព ពីព័ត៌មានស្តីពីគ្រោះអាសន្ន ។

- *ប្រសិនបើលោកអ្នកស្គាល់បុគ្គលដែលមិនអាច យល់ មើលឃើញ ឬដឹងឮ អំពីសារនេះបានទេសូមជួយប្រាប់ពួកគេផង ។*

តំណរបណ្តាញដែលមានប្រយោជន៍ ៖

http://mil.wa.gov/emergency-management-division/hazards/hazardous-material

http://www.ready.gov/hazardous-materials-incidents

http://www.redcross.org/prepare/disaster/chemical-emergency